# ក្រុមការពារក្តីជនសង្ស័យម្នាក់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
# Defence Team for a Named Suspect at the ECCC

**<u>សេចក្តីប្រកាសព័ត៌មាន: ភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣</u>**

**<u>សហចៅក្រមស៊ើបអង្កេតត្រូវតែធានានូវការប្រព្រឹត្តស្មើភាពគ្នាចំពោះគ្រប់ភាគីក្នុងសំណុំរឿង០០៤</u>**

សហមេធាវីការពារក្តីជនសង្ស័យម្នាក់ក្នុងសំណុំរឿង០០៤ (អត្តសញ្ញាណរបស់ជនសង្ស័យត្រូវស្ថិតក្នុងការសម្ងាត់ក្នុងដំណាក់កាលស៊ើបអង្កេត) នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមអំពាវនាវឲ្យ សហចៅក្រមស៊ើបអង្កេត ចាត់វិធានការជាបន្ទាន់ដើម្បីធានានូវការគោរពសិទ្ធិក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌របស់កូនក្តីពួកយើង និងដើម្បីធានានូវការប្រព្រឹត្តដោយស្មើភាពគ្នាចំពោះភាគីផ្សេងៗក្នុងសំណុំរឿង ០០៤ ដោយផ្តល់នូវសិទ្ធិពិនិត្យឯកសារសំណុំរឿងដល់ជនសង្ស័យជាបន្ទាន់។

ច្បាប់ជាធរមានរបស់អង្គជំនុំជម្រះវិសាមញ្ញ បានចែងយ៉ាងច្បាស់លាស់ពីការធានានូវសិទ្ធិរបស់គ្រប់ភាគីក្នុងការមើលឯកសារសំណុំរឿង ក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។ យ៉ាងណាមិញ រយៈពេលមួយឆ្នាំបន្ទាប់ពីកូនក្តីបានជ្រើសរើស លោក មុំ លុដ្ឋ ជាសហមេធាវីជាតិ និងលោក Richard Rogers ជាសហមេធាវីអន្តរជាតិ និងរយៈពេលជាងប្រាំពីរខែបន្ទាប់ពីកូនក្តីបានជ្រើសរើសលោកមេធាវី Göran Sluiter ជាសហមេធាវីអន្តរជាតិទី២ សំណុំរឿងប្រឆាំងនឹងកូនក្តីរបស់យើង បានដំណើរការនីតិវិធីទៅមុខដោយមិនមានការផ្តល់សិទ្ធិមើលឯកសារសំណុំរឿងដល់រូបគាត់។ ជនសង្ស័យ ត្រូវប្រឈមនឹងការចោទប្រកាន់ ដោយមិនបានទទួលបាននូវព័ត៌មានពីលក្ខណៈ និងដើមចមនៃបទចោទប្រកាន់ទាំងនោះ។

ការប្រព្រឹត្តចំពោះជនសង្ស័យ មានការផ្ទុយស្រឡះពីការប្រព្រឹត្តចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤។ នៅខែ មេសា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត Mark Harmon បានចេញសេចក្តីសម្រេចផ្តល់លទ្ធភាពដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចំនួន២០រូប ចូលទៅពិនិត្យឯកសារសំណុំរឿង។ នៅក្នុងសេចក្តីសម្រេចរបស់គាត់ ចៅក្រម Harmon បានបកស្រាយថា "មេធាវីដែលត្រូវបានទទួលស្គាល់មានសិទ្ធិពិនិត្យ និងថតចម្លងឯកសារដើមនៃសំណុំរឿងស្តីពីការស៊ើបអង្កេត ដែលកូនក្តីរបស់ខ្លួនជាភាគី"។ ប៉ុន្តែនៅក្នុងដីកាសម្រេចចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ ដែលចៅក្រម Harmon បានប្រកាសទទួលស្គាល់លោក មុំ លុដ្ឋ

និង លោក Göran Sluiter ជាសហមេធាវីសម្រាប់ជនសង្ស័យ លោកចៅក្រម បានធ្វេសប្រហែសមិនបានផ្តល់សិទ្ធិក្នុងការពិនិត្យឯកសារសំណុំរឿងដល់មេធាវីទាំងពីរទេ។ ការខកខាននេះ ពិតជាពិបាកយល់បានណាស់ ព្រោះថាច្បាប់ជាធរមានរបស់អង្គជំនុំជម្រះ បានចែងយ៉ាងច្បាស់ពីការធានានូវសិទ្ធិក្នុងការមើលឯកសារសំណុំរឿង ហើយម្យ៉ាងទៀតសេចក្តីសម្រេចរបស់លោកចៅក្រមខ្លួនឯងបានទទួលស្គាល់ថា មេធាវីដែលបានទទួលស្គាល់ មានសិទ្ធិពិនិត្យឯកសារសំណុំរឿង។

ភាពផ្ទុយគ្នានៃការប្រព្រឹត្តិចំពោះជនសង្ស័យ និងចំពោះដើមបណ្តឹងរដ្ឋប្បវេណី គឺជាការរំលោភទៅលើសិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបាននូវការតតាំងដោយយុត្តិធម៌ក្នុងដំណាក់កាលនីតិវិធី និងទៅលើសមភាពនៃសិទ្ធិរបស់ភាគីនីមួយៗ គឺរវាង ព្រះរាជអាជ្ញា, ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមការពារក្តី។ ស្ថានភាពនាពេលបច្ចុប្បន្ន បានបង្ហាញពីឋានានុក្រមនៃសិទ្ធិកំពុងអនុវត្តនៅអង្គជុំនុំជំរះវិសាមញ្ញ ពោលគឺសិទ្ធិរបស់ជនសង្ស័យមានលក្ខណៈឋិតនៅក្រោមព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ ដើម្បីធានាអោយមានការគោរពដល់សិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ សហចៅក្រមស៊ើបអង្កេត ត្រូវតែផ្តល់លទ្ធភាពអោយក្រុមការពារក្តីបានមើលឯកសារសំណុំរឿងជាបន្ទាន់។ ការខកខានក្នុងការផ្តល់លទ្ធភាពពិនិត្យឯកសារសំណុំរឿង នឹងធ្វើឲ្យប៉ះពាល់ដល់ភាពសុច្ចរិតនៅក្នុងដំណើការនីតិវិធីនៃសំណុំរឿង០០៤ទាំងមូល។

បន្ថែមពីនេះទៅទៀត ដោយហេតុថាសហព្រះរាជអជ្ញានៅក្នុងតុលាការអន្តរជាតិ និងក្នុងតុលាការកូនកាត់ មានតួនាទីធានាអោយមានសមភាពចំពោះមុខច្បាប់ និងភាពយុត្តិធម៌នៅក្នុងដំណើរការនីតិវិធី, សហមេធាវីការពារក្តី ស្នើសុំឲ្យសហព្រះរាជអាជ្ញា បញ្ចេញមតិយោបល់របស់ខ្លួនចំពោះការទទួលបានលទ្ធភាពស្មើគ្នាក្នុងការចូលពិនិត្យឯកសារសំណុំរឿង។

ព័ត៌មានបន្ថែម សូមទាក់ទងលោក Göran Sluiter តាមរយៈអ៊ីម៉ែល: gsluiter@bohler.eu

សហមេធាវីសម្រាប់ជនសង្ស័យ

មុំ លុជ្ស    Richard Rogers    Göran Sluiter